មជ្ឈមណ្ឌលឯកសារកម្ពុជា

**ប៉ុក ជីម , ភេទប្រុស K01526 (បាត់ខ្លួន)**

**អន្តភាពៈ ជំនួយការសហករណ៍ស្វាយ,តំបន់ ៤**

**សម្ភាសន៍ជាមួយ អ៊ួច ណាប់, អាយុ ៥៧ ឆ្នាំ “ត្រូវជាប្រពន្ធ”**

**នៅភូមិបាសែត ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់តំបង**

**ថ្ងៃទី ១៤ កក្កដា ឆ្នាំ២០០៦**

**សម្ភាសន៍ដោយៈ វ៉ា នៃវ៉ាន់**

នៃ វ៉ាន់: អ៊ុំឈ្មោះអីដែរ?

ណាប់: ឈ្មោះអ៊ួចបណាប់ ។

នៃ វ៉ាន់: អ៊ួច ណាប់មិនមែនដាក់យ៉ាន ណាប់ទេហ្អែស៎?

ណាប់: ចា៎! ណឹងម៉ែទេ ។

នៃ វ៉ាន់: អីចឹងដាក់យ៉ានណាប់វិញហ្អែស៎?

ណាប់: ចា៎! ម្ដាយខ្ញុំទេយ៉ាននោះ ។

នៃ វ៉ាន់: សព្វថ្ងៃអ៊ំអាយុប៉ុន្មានហើយ?

ណាប់: ៥៧

នៃ វ៉ាន់: ៥៧ ឆ្នាំហើយហ្អែស?

ណាប់: ចា៎!

នៃ វ៉ាន់: អ៊ុំកើតឆ្នាំខ្មែរឆ្នាំអីដែរ?

ណាប់: អត់ដឹង..ខ្ញុំអត់ចាំ ។

នៃ វ៉ាន់: សត្វអីៗ...

ណាប់: អូ..!សត្វៗណឹងហ្អែស...ឆ្នាំខាល ។

នៃ វ៉ាន់: អ៊ុំមានស្រុកកំណើតនៅឯណាដែរ?

ណាប់: ស្រុកកំណើតកើតនៅភូមិបាសែតណឹង ។

នៃ វ៉ាន់: ចុះឃុំ?

ណាប់៖ ឃុំតាប៉ុន ។

ផៃ ក៏ន់៖ ស្រុកសង្កែ?

ណាប់៖ ចា៎!

ផៃ ក៏ន់៖ ចុះសព្វថ្ងៃអ៊ុំរស់នៅភូមិឃុំអីដែរ?

ណាប់៖ នៅភូមិបាសែតនេះឯង ។

ផៃ ក៏ន់៖ ភូមិបាសែត ឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបងណឹង...?

ណាប់៖ ចា៎!

ផៃ ក៏ន់៖ បា! ឪពុកម្តាយអ៊ុំ ឈ្មោះអីដែរ?

ណាប់៖ ឪពុកឈ្មោះ អ៊ូច, ម្តាយឈ្មោះ យ៉ាន ។

ផៃ ក៏ន់៖ ឪពុកឈ្មោះ អ៊ូច, ម្តាយឈ្មោះ យ៉ាន?

ណាប់៖ ចា៎!

ផៃ ក៏ន់៖ បា! សព្វថ្ងៃគាត់ទាំងពីរនាក់រស់ឬក៏ស្លាប់?

ណាប់៖ គាត់ស្លាប់អស់ហើយ ។

ផៃ ក៏ន់៖ គាត់ស្លាប់ជំនាន់ណា?

ណាប់៖ ចប់ហើយ...ម្តាយ ហើយឪពុកខ្ញុំគាត់ខូចតាំងពីខ្មែរក្រហមម្លេះ ។

ផៃ ក៏ន់៖ បាទ! អ៊ុំមានបងប្អូនប៉ុន្មាននាក់?

ណាប់៖ នៅសល់សព្វថ្ងៃ ៥ នាក់ ។

ផៃ ក៏ន់៖ ចុះទាំងរស់ទាំងស្លាប់ប៉ុន្មាននាក់?

ណាប់៖ ទាំងរស់ទាំងស្លាប់ ៩ នាក់ ។

ផៃ ក៏ន់៖ ៩ នាក់ណឹងស្រីប៉ុន្មានប្រុសប៉ុន្មាន?

ណាប់៖ ប្រុស ៣ ស្រី ៦ ។

ផៃ ក៏ន់៖ សព្វថ្ងៃនៅ ៦ នាក់?

ណាប់៖ ចា៎!

ផៃ ក៏ន់៖ ៦ នាក់ណឹងស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ណាប់៖ ស្រីទាំងអស់ ។

ផៃ ក៏ន់៖ ប្រុសៗស្លាប់អស់?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ស្លាប់ជំនាន់ណា?

ណាប់៖ ស្លាប់កាលយួនផង ហើយកាលខ្មែរក្រហមផង ។

នៃ វ៉ាន់៖ បងប្អូនអ៊ុំទាំង ៦នាក់ហ្នឹងរស់នៅក្នុងភូមិឃុំហ្នឹងជាមួយគ្នាឬក៏រស់នៅផ្សេង?

ណាប់៖ ចា៎! នៅជិតៗគ្នាដែរ ។

នៃ វ៉ាន់៖ ចុះលោកអ៊ុំ ប៉ុក ជឹមហ្នឹងត្រូវជាម៉េចជាមួយអ៊ុំដែរ?

ណាប់៖ ប៉ុក ជឹម ហ្នឹងត្រូវជាប្តីខ្ញុំ ។

នៃ វ៉ាន់៖ បាទត្រូវជាប្តីអ៊ុំ..! អ៊ុំតាមអ៊ុំចាំប៉ុក ជឹម គាត់កើតឆ្នាំណាដែរ?

ណាប់៖ គាត់កើតឆ្នាំឆ្លូវ

នៃ វ៉ាន់៖ អូឆ្នាំឆ្លូវ..! បើតាមអ៊ុំស្មានគាត់មៅទល់ឥឡូវគាត់អាយុប៉ុន្មានហើយ?

ណាប់៖ ចុះឆ្លូវហើយ និងខាល ។

នៃ វ៉ាន់៖ បង ១ ឆ្នាំ...ហើយជឹមហ្នឹងគាត់មានកំណើតកើតជានៅឯណាដែរ?

ណាប់៖ កើតនៅស្រុកហ្នឹង និងស្រុកហ្នឹងដែរ ។

នៃ វ៉ាន់៖ កើតនៅភូមិបាសែតហ្នឹងដែរ?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ឃុំតាប៉ុនហ្នឹង?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ដូចថាពីក្មេងៗមៅអ៊ុំស្គាល់គ្នាតាំងពីក្មេងៗមៅឬក៏យ៉ាំងម៉េច?

ណាប់៖ ស្គាល់គ្នាតាំងពីក្មេងៗមៅ ។

នៃ វ៉ាន់៖ អូ..! ស្គាល់គ្នាតាំងពីក្មេងៗមៅដែរហ្អស៎?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ឪពុកម្តាយរបស់ជឹមហ្នឹងឈ្មោះអីដែរ?

ណាប់៖ ឈ្មោះតាប៉ុក ។

នៃ វ៉ាន់៖ ឪពុកឈ្មោះតាប៉ុក?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ចុះម្តាយ?

ណាប់៖ ម្ដាយឈ្មោះយាយគុម ។

នៃ វ៉ាន់៖ យាយគុម ហ្អែស៎?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ សព្វថ្ងៃគាត់ទាំងពីរនាក់ខូចអស់ហើយ?

ណាប់៖ ខូចអស់ហើយ ។

នៃ វ៉ាន់៖ ខូចតាំងពីជំនាន់ណាទៅ ។

ណាប់៖ ខូចយូរហើយ ។

នៃ វ៉ាន់៖ តាំងជំនាន់ណាទៅ?

ណាប់៖ ខ្ញុំមិនសូវចាំផង ។

នៃ វ៉ាន់៖ តាំងមុនខ្មែរក្រហមទៀត ។

ណាប់៖ ចា៎! ខ្ញុំមិនទាន់ស្គាល់គាត់ច្បាស់ផង ។

នៃ វ៉ាន់៖ ខូចទាំងពីរនាក់ហ្នឹង?

ណាប់៖ បើឪគាត់ខូចកាលខ្មែរក្រហម ។

នៃ វ៉ាន់៖ ឈឺហ្អែស៎? ដឹមហ្នឹងគាត់មានបងប្អូនទាំងអស់ប៉ុន្មាននាក់ដែរអ៊ុំ?

ណាប់៖ រាប់ទាំងអស់ហ្អែស៎ទាំងស្លាប់ទាំងរស់ហ្អែស៎?

នៃ វ៉ាន់៖ បាទ!

ណាប់៖ ជឿន, ចក់...អាជឿនហ្នឹងបងគេ...

នៃ វ៉ាន់៖ អីចឹង...?

ណាប់៖ អ៊ឺ...! ហ៊ឺ...អាចក់ប្អូន ៣... អត់ដឹងថាបងប្អូនគាត់មានប៉ុន្មានទេខ្ញុំ...រាប់ទាំងអស់ទាំងស្លាប់ទាំងរស់ម៉ង...

នៃ វ៉ាន់៖ រាប់ទាំងអស់ទាំងស្លាប់ទាំងរស់ម៉ងប៉ុន្មាននាក់...

ណាប់៖ ជឿន, ចក់, អាជឿនបងគេហ្អាស៎...អាចក់ប្អូន ៣.., ៤ ជឿន, ៥ អ្នកធុង, ៦ អ្នកយ៉ៃ, ៧ អ្នក យឿន ។

នៃ វ៉ាន់៖ បងប្អូនទាំងអស់ ៧ នាក់?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ៧ នាក់ហ្នឹងរាប់ទាំងគាត់ហ្អែស៎?

ណាប់៖ 	ចាំ!

នៃ វ៉ាន់៖ 	ក្នុងចំណោម ៧ នាក់ណឹងប្រុសប៉ុន្មានស្រីប៉ុន្មានដែរ?

ណាប់៖ 	ប្រុស ៣ នាក់ស្រី ៤នាក់ ។

នៃ វ៉ាន់៖ 	ចុះសព្វថ្ងៃនៅសល់ប៉ុន្មាននាក់?

ណាប់៖ 	អូ..ភ្លេចនៅ ១ ទៀតអីណោះ...

នៃ វ៉ាន់៖ 	៨ ហ្អែស៎?

ណាប់៖ 	ចាំ!

នៃ វ៉ាន់៖ 	ប្រុស៣ ស្រី ៥?

ណាប់៖ 	ចាំ!

នៃ វ៉ាន់៖ 	ចុះសព្វថ្ងៃនៅរស់ប៉ុន្មាននាក់?

ណាប់៖ 	នៅរស់ ៥ នាក់ ។

នៃ វ៉ាន់៖ 	ស្រីប៉ុន្មាននាក់?

ណាប់៖ 	ស្រីទាំង ៥ នាក់ ។

នៃ វ៉ាន់៖ 	អស់ប្រុស ៣ នាក់?

ណាប់៖ 	ចាំ!

នៃ វ៉ាន់៖ 	ប្រុសណឹងគាត់បាត់ខ្លួនសម័យខ្មែរក្រហមឬក៏ទើបតែស្លាប់ក្រោយនេះទេ?

ណាប់៖ 	គាត់ស្លាប់កាលសម័យខ្មែរក្រហមណឹងឯង ។

នៃ វ៉ាន់៖ 	បងប្អូនគាត់ ២ នាក់ណឹងហ្អែស៎?

ណាប់៖ 	ចាំ!

នៃ វ៉ាន់៖ 	ចុះអ៊ុំដូចថាដឹមកាលពីក្មេងៗគាត់មានបានរៀនសូត្រអីដែរទេ?

ណាប់៖ 	អត់បានរៀនសូត្រអីទេ ។

នៃ វ៉ាន់៖ 	ហេតុអីបានគាត់អត់បានរៀន?

ណាប់៖ 	ហេតុម៉ែអំពីក្រ រវល់ខំរកស៊ី ។

នៃ វ៉ាន់៖ 	ចុះគាត់មានបានបួសអីដែរអត់?

ណាប់៖ 	អត់ ។

នៃ វ៉ាន់៖ 	បាទ!អីចឹងគាត់នៅរកស៊ីធ្វើស្រែជាមួយឪពុកម្ដាយអីចឹងទៅ?

ណាប់៖ ចាំ!

នៃ វ៉ាន់៖ គាត់ធ្វើស្រែឬក៏រកស៊ីដែរ?

ណាប់៖ ធ្វើតែស្រែ ។

នៃ វ៉ាន់៖ ចុះអ៊ុំរៀបការជាមួយគាត់ឆ្នាំណាទៅ?

ណាប់៖ ភ្លេចអស់ហើយយូរហើយ ។

នៃ វ៉ាន់៖ អ៊ុំការហើយរយៈពេលប៉ុន្មានបានអ៊ុំមានកូន?

ណាប់៖ ការហើយឆ្នាំណឹងឯងមានកូនឆ្នាំណឹងឯង ។

នៃ វ៉ាន់៖ អូ..!កូនមៅដល់សព្វថ្ងៃអាយុប៉ុន្មានហើយ?

ណាប់៖ អាយុ ៣៧ ហ្អែ...

នៃ វ៉ាន់៖ គាត់កើតឆ្នាំអី?

ណាប់៖ ឆ្នាំច...៣៧ ហើយ ។

នៃ វ៉ាន់៖ ៣៧ ឆ្នាំហ្អែស់?

ណាប់៖ ចាំ!

នៃ វ៉ាន់៖ អីចឹងអ៊ុំការមុនរដ្ឋប្រហារទម្លាក់សម្តេចឬក៏ក្រោយរដ្ឋប្រហារទម្លាក់សម្តេច?

ណាប់៖ មុន ។

នៃ វ៉ាន់៖ មុនរដ្ឋប្រហារទម្លាក់សម្តេចទៀត?

ណាប់៖ ចាំ!

នៃ វ៉ាន់៖ មុនប្រហែលរយៈពេលប៉ុន្មានដែរអ៊ុំ?

ណាប់៖ ទេខ្ញុំអត់ចាំ ។

នៃ វ៉ាន់៖ ចុះពេលដែលអ៊ុំរៀបការណឹងឪពុកម្តាយរៀបចំឲ្យឬក៏ស្រឡាញ់គ្នា?

ណាប់៖ ស្រឡាញ់ខ្លួនឯង ។

នៃ វ៉ាន់៖ កាលៀណឹងយ៉ាងម៉េចបាស្គាល់ស្រឡាញ់ខ្លួនឯង?

ណាប់៖ នៅជិតគ្នា ។

នៃ វ៉ាន់៖ ចុះពេលការហើយអ៊ុំប្រកបរបររកស៊ីអីខ្លះ?

ណាប់៖ រកស៊ីធ្វើស្រែណឹងណាំ ។

នៃ វ៉ាន់៖ ធ្វើស្រែរហូតដល់ឆ្នាំណាទៅបានឈប់?

ណាប់៖ ធ្វើស្រែដល់តែកើតខ្មែរក្រហមណឹង គំពង់តែនៅស្រែណឹងគេគៀយកទៅណឹងឯង ។

នៃ ភ័ន់៖ ការហើយរយៈពេលប្រហែលប៉ុន្មានបានខ្មែរក្រហមគេគៀយកទៅណឹង?

ណាប់៖ បានកូន ១ ។

នៃ ភ័ន់៖ កូន ១ អាយុប្រហែលប៉ុន្មានបានគេគៀ?

ណាប់៖ ប្រហែលជាមួយខួបហើយ ។

នៃ ភ័ន់៖ អ៊ីចឹងពេលក្រោយរដ្ឋប្រហារទម្លាក់សម្ដេចណឹងគេគៀឬក៏ក្រោយរដ្ឋប្រហា?

ណាប់៖ គេគៀ...

នៃ ភ័ន់៖ គេគៀណឹងមុនឬក៏ក្រោយរដ្ឋប្រហារទម្លាក់សម្ដេច?

ណាប់៖ ខ្ញុំអត់ដឹងផង ។

នៃ ភ័ន់៖ អ៊ុំការហើយបានកូនមួយហើយបានគេគៀហ្អែស..កូនប្រុសហ្អែស?

ណាប់៖ កូនស្រី ។

នៃ ភ័ន់៖ ឈ្មោះអី?

ណាប់៖ ឈ្មោះសម្បត្តិ ។

នៃ ភ័ន់៖ អ៊ីចឹងការហើយមានកូនអាយុមួយខួបបានគេគៀ?

ណាប់៖ ហ្នឹងហើយ!

នៃ ភ័ន់៖ អ៊ីចឹងបើគិតពីការហើយបាន ១ ឆ្នាំហើយ នឹងពរពោះណឹងវាពីរឆ្នាំដែរអ៊ីចឹង ។

ណាប់៖ អត់ដឹង ។

នៃ ភ័ន់៖ ចាំមើលអ៊ុំការវាមិន ៧ខែ..មិន ៩ខែ ការហើយបានមួយឆ្នាំអ៊ុំបានកូន ១ ហើយកូនបានមាខួបអ៊ីចឹងអាយុចង់ចូល ២ ឆ្នាំហើយបានខ្មែរក្រហមគេគៀមិនចឹង?

ណាប់៖ អ៊ុំចឹងហើយ ។

នៃ ភ័ន់៖ កាលណឹងគៀគេគ្រួសារអ៊ុំហើយកូនមួយណឹង ៣ នាក់ណឹង?

ណាប់៖ ចាំ!

នៃ ភ័ន់៖ កាលណឹងអ៊ុំធ្វើស្រែនៅអីណា?

ណាប់៖ នៅវាលកើត ។

នៃ ភ័ន់៖ គៀណឹងគេគៀយកទៅនៅឯណា?

ណាប់៖ នៅក្នុងព្រៃ ។

ផៃ ភ៉ន់: ព្រៃនៅឯណាទៅអ៊ុំ?

ណាប់: ព្រៃនាម ។

ផៃ ភ៉ន់: ព្រៃនាមម៉ាជំនៀងជិតបឹងទន្លេសាបអីណឹងហ្អេស?

ណាប់: ហ្នឹងហើយ ។

ផៃ ភ៉ន់: កាលណឹងបើគេគៀទៅ ហើយយើងអត់ទៅយ៉ាងម៉េចទៅ?

ណាប់: យើងអត់ទៅ គេវ៉ៃយើងចោល ។

ផៃ ភ៉ន់: កាលគៀណឹងមានតែបីនាក់អ៊ុំណឹងទេ?

ណាប់: ចា៎! នៅនឹងស្រែណឹង ។

ផៃ ភ៉ន់: អត់មានអ្នកភូមិគៀទៅជាមួយទេ?

ណាប់: អត់ទេ ។

ផៃ ភ៉ន់:

ពេលគៀទៅដល់ព្រៃនាមជិតបឹងទន្លេសាបណឹងដូចថាអ៊ុំមានឃើញអ្នកផ្សេងរស់នៅច្រើន ហ្អីម៉េង?

ណាប់: ចា៎!រស់នៅច្រើន ឲ្យទៅរស់នៅនឹងគេឯងហ្នឹងទៅ ។

ផៃ ភ៉ន់: ពេលទៅដល់ណឹងអ៊ុំធ្វើអីទៅ ?

ណាប់: មានធ្វើអីនៅ តែកន្លែងណឹងទៅ ។

ផៃ ភ៉ន់: ចុះជីមគាត់ធ្វើអីទៅ?

ណាប់: ជីមគេចេះតែប្រើមិនដឹងទៅណាទៅណីទៅ ។

ផៃ ភ៉ន់: អ៊ុំមានដឹងថាគាត់ធ្វើអីដែរអត់?

ណាប់: មិនដឹងថាធ្វើស្អីទេឃើញតែគេហៅប្រើទៅណេះទៅឈណោះ ។

ផៃ ភ៉ន់: អីចឹងពេលណឹងគាត់ធ្វើការឲ្យខ្មែរក្រហមហើយន៎ស?

ណាប់: តែទៅធ្វើការឲ្យគេហើយបើមិនធ្វើបានអីហូប ។

ផៃ ភ៉ន់: អ៊ុំអត់ដឹងទេន៎ស..គាត់ទៅធ្វើគេ?

ណាប់: មិនដឹងទៅធ្វើអីទៅបាត់ៗទៅ ។

ផៃ ភ៉ន់: ទៅបាត់ៗទៅ?

ណាប់: ចា៎!

នៃ ពាន់ៈ ចុះអ៊ុំនៅផ្ទះធម្មតា?

ណាប់ៈ ចាំ!

នៃ ពាន់ៈ អត់មានធ្វើស្រែធ្វើអីទៀតទេ?

ណាប់ៈ គ្មានធ្វើអីទេ ។

នៃ ពាន់ៈ ចុះបានអីហូបទៅ?

ណាប់ៈ គេឲ្យហូប ។

នៃ ពាន់ៈ គេឲ្យហូប?

ណាប់ៈ ចាំ!

នៃ ពាន់ៈ កាលជំនាន់ណឹងពេលទៅដល់ភ្លាមគេឲ្យហូបតាមធម្មតាឬយ៉ាងម៉េច?

ណាប់ៈ គេឲ្យហូបធម្មតា ។

នៃ ពាន់ៈ ហូបឆ្អែតដូចយើងនៅផ្ទះធម្មតាអីចឹង?

ណាប់ៈ ចាំ!

នៃ ពាន់ៈ ចុះអ៊ុំនៅព្រៃនាមណឹងរហូតដល់ឆ្នាំណាបានគេការចេញមកវិញ ។

ណាប់ៈ ៧៥ ។

នៃ ពាន់ៈ ៧៥ ពេលខ្មែរក្រហមចូលកាន់បាត់ដំបងណឹងហ្អែស?

ណាប់ៈ ចាំ!

នៃ ពាន់ៈ ៧៥ គេគៀយកមកឯណាវិញទៅ?

ណាប់ៈ គេឲ្យមកនៅតាប៉ុន ។

នៃ ពាន់ៈ អោយមកនៅភូមិឃុំអ៊ុំរាល់ថ្ងៃវិញណឹង?

ណាប់ៈ ចាំ! មិនមែននៅភូមិនេះទេនៅភូមិ តាប៉ុន ។

នៃ ពាន់ៈ តែគ្រួសារអ៊ុំឬមានអ្នកផ្សេងមកដែរ?

ណាប់ៈ គេទាំងអស់គ្នាមកដែរ ។

នៃ ពាន់ៈ បាទ! ពេលដែលមកដល់ភូមិតាប៉ុនណឹងដឹមគាត់នៅ ធ្វើការបំរើខ្មែរក្រហមដែរឬក៏ឈប់ហើយ?

ណាប់ៈ នៅបំរើគេណឹងឯង ។

នៃ ពាន់ៈ ការងារគាត់កាន់ខាងអីទៅ ពេលមកនៅតាប៉ុនណឹង?

ណាប់៖ ធ្វើមេកងស្អីទេ...មិនស្កាល់ទេខ្ញុំ ។

ឆែ វ៉ាន់៖ អូ..អត់ស្គាល់ហ្អែស៎?

ណាប់៖ ចា៎!

ឆែ វ៉ាន់៖ ជំនួយការសហករណ៍...

ណាប់៖ ខ្ញុំមិនចាំទេកាលណឹងនោះ ។

ឆែ វ៉ាន់៖ បាទ! គាត់ធ្វើការនៅភូមិនៅឃុំឬនៅស្រុកពេលគាត់មោ៉ដល់តាប៉ុនណឹង?

ណាប់៖ ឃើញតែគេដើរហៅគ្នីហៅគ្នាប្រជុំតែមិនដឹងថាគេធ្វើអីខ្ញុំមិនស្គាល់ ។

ឆែ វ៉ាន់៖ អីចឹងគាត់នៅតាប៉ុនណឹងរហូតដល់គេចាប់ខ្លួនឬក៏គេប្តូរទៅណា?

ណាប់៖ គេប្តូរ ។

ឆែ វ៉ាន់៖ អោយទៅនៅឯណា?

ណាប់៖ ទៅនៅអូរម្នីទៀត ។

ឆែ វ៉ាន់៖ គាត់នៅតាប៉ុនបានរយៈពេលប៉ុន្មានបានគេប្តូទៅអូម្នី?

ណាប់៖ នៅពីរបីខែដែរណឹង ។

ឆែ វ៉ាន់៖ នៅរយៈពេលខ្លីដែរហ្អែស...? គេប្តូរទៅអូរម្នី?

ណាប់៖ ចា៎!

ឆែ វ៉ាន់៖ អូរម្នីណឹងឃុំអូរម្នីដែរហ្អែស៎?

ណាប់៖ មិនដឹងអីទេ ។

ឆែ វ៉ាន់៖ ឃុំអន្លង់វិល...

ណាប់៖ អូរម្នីវាអន្លង់វិលទេដឹង...មិនដឹងទេ ។

ឆែ វ៉ាន់៖ ពេលទៅអូរម្នីណឹងអ៊ំទៅជាមួយគាត់ដែរឬទៅតែគាត់ទេ?

ណាប់៖ ចា៎! ទៅទាំងអស់ ។

ឆែ វ៉ាន់៖ ពេលទៅដល់អូរម្នីណឹងគាត់ធ្វើការអីទៅ?

ណាប់៖ ណឹងគេឲ្យកាន់សហករណ៍ ។

ឆែ វ៉ាន់៖ សហករណ៍អីអាណឹង? ជំនួយការអី?

ណាប់៖ មិនដឹងសហករណ៍អី...គេថាសហករណ៍ៗនឹងគេទៅ ។

ផៃ រ៉ាន់ៈ បាទ! ចុះពេលទៅសហករណ៍គេមានប្តូរពីណើងទៅទៀតទេ?

ណាប់ៈ ទៅទៀត ។

ផៃ រ៉ាន់ៈ ទៅនៅណាទៀត?

ណាប់ៈ ទៅនៅស្វាយ ។

ផៃ រ៉ាន់ៈ បន្ទាប់មោ៉ទៅនៅស្វាយ?

ណាប់ៈ ចា៎!

ផៃ រ៉ាន់ៈ ចុះនៅសហករណ៍អូរម្ទីណើងនៅបានរយៈពេលប៉ុន្មានដែរ?

ណាប់ៈ ប្រហែល ១ ឆ្នាំ បានពួកនារតីមោ៉ ។

ផៃ រ៉ាន់ៈ នៅប្រហែលបាន ១ ឆ្នាំ?

ណាប់ៈ ចា៎!

ផៃ រ៉ាន់ៈ អីចឹងពេល ៧៥ ខ្មែរក្រហមកាន់គាត់ចេញពីព្រៃនាមមោ៉ មោ៉នៅភូមិតាប៉ុននេះបានតែពីរបីខែទេ?

ណាប់ៈ ចា៎!

ផៃ រ៉ាន់ៈ ពីរបីខែក្រោយមោ៉ទៀតគេជម្លៀសទៅនៅអូម្ទី?

ណាប់ៈ ចា៎!

ផៃ រ៉ាន់ៈ គេឲ្យទៅធ្វើខាងសហករណ៍ដែរទេ?

ណាប់ៈ ធ្វើសហករណ៍ណើងឯង ។

ផៃ រ៉ាន់ៈ ក្រោយមោ៉ទៀបានគេប្តូរគាត់ទៅនៅខាងស្វាយ..សហករណ៍ស្វាយ?

ណាប់ៈ ចា៎

ផៃ រ៉ាន់ៈ គាត់នៅអូរម្ទីណើងអស់រយៈពេលជាង ១ ឆ្នាំទេហ្អស់?

ណាប់ៈ ប៉ុណ្ណឹងឯង ។

ផៃ រ៉ាន់ៈ បា! ពេលគាត់ទៅនៅស្វាយណើងខាងនារតីចាត់តាំងឲ្យទៅនៅឬក៏...?

ណាប់ៈ នារតី ។

ផៃ រ៉ាន់ៈ ពេលណើងនារតីចូលមោ៉ពេញស្រុកភូមិណើងអស់ហើយហ្អែស?

ណាប់ៈ ចា៎!

ផៃ រ៉ាន់ៈ ពេលដែលនារតីចូលមោ៉ណើងពេលណើងពួកនារតីចាប់ផ្តើមដកពួកបូពា៌ខ្ទះឬនៅ?

ណាប់៖ កាលណឹងពួកណឹងមៅហើយគេឲ្យយើងដកចេញ គេឲ្យទៅ នៅវត្តស្វាយ ។

នៃ រ៉ាន់៖ ពួកនារតីចូលមៅប្រហែលជាឆ្នាំណាដែរអ៊ុ ?

ណាប់៖ ឆ្នាំ ៧៦ ណឹងឯង ។

នៃ រ៉ាន់៖ ចូល ៧៦...

ណាប់៖ ៧៦ ណឹងហើយព្រោះចុង ៧៧ ចាប់បាត់អស់ហើយ ។

នៃ រ៉ាន់៖ បាទ!អីចឹងនារតីចូលតាំង ៧៦ មៅ?

ណាប់៖ ទេខ្ញុំមិនហ៊ានថាទេខ្លាចលោខ្ញុំភ្លេច ។

នៃ រ៉ាន់៖ អីចឹងហ្អែស?

ណាប់៖ ចា៎!

នៃ រ៉ាន់៖ ពេលពួកនារតីចូលមៅណឹងប្រហែលជាឆ្នាំណាបានវៀតណាមចូលមៅដល់?

ណាប់៖ ...?

នៃ រ៉ាន់៖ ដូចថាពួកនារតីផ្លាស់មៅកាន់ខាងពាយ័ព្យណឹងបានប៉ុន្មានខែប៉ុន្មានឆ្នាំដែរបានវៀតណាមគេវ៉ៃចូលរំដោះប្រជាជនយើងវិញហ្អាស?

ណាប់៖ ខ្ញុំអត់ចាំ...

នៃ រ៉ាន់៖ តាមអ៊ុំស្មានប្រហែលរយៈពេលប៉ុន្មានដែរ?

ណាប់៖ អត់ហ៊ានថា ។

នៃ រ៉ាន់៖ ពេលផ្លាស់មៅស្វាយណឹងផ្លាស់ទាំងគ្រួសារមៅដែរហ្អែស?

ណាប់៖ ចា៎! គេដកទៅទាំងអស់ ។

នៃ រ៉ាន់៖ សហករណ៍ស្វាយណឹងនៅក្នុងឃុំអីដែរអ៊ុំ ?

ណាប់៖ អត់ស្គាល់ផងទៅ នៅ បានបន្តិច ។

នៃ រ៉ាន់៖ ទៅ នៅ បានបន្តិចវៀតណាមចូល?

ណាប់៖ អត់ទេខ្ញុំមៅវិញ ។

នៃ រ៉ាន់៖ អ៊ុំមៅនៅភូមិឃុំណឹងវិញ?

ណាប់៖ ចា៎! អត់មានប្តីខ្ញុំរត់មៅវិញ ។

នៃ រ៉ាន់៖ បាទ!ដូចថានៅស្វាយណឹងតួនាទីគាត់ជាអីដែរ?

ណាប់ៈ ចាស៎?

ឆែ វ៉ន់ៈ ពេលគាត់ទៅ នៅសហករណ៍ស្វាយណឹងតួនាទីគាត់ជាអីដែរ?

ណាប់ៈ គាត់គ្មានធ្វើទេនៅស្វាយណឹង គ្រាន់តែនាំកម្លាំងទៅ ច្រូតកាត់ប៉ុណ្ណឹងឯង ។

ឆែ វ៉ន់ៈ អាការងាររបីមុនម៉ោក៏នាំកម្លាំងទៅ ច្រូតកាត់អីចឹងដែរ?

ណាប់ៈ ចា៎!

ឆែ វ៉ន់ៈ ច្រូតកាត់នៅជិតៗណឹងទេឬក៏ទៅឆ្ងាយដែរ?

ណាប់ៈ នៅក្បាលថ្នល់អ៊ីណោះ កាច់រទេះឯណោះ ។

ឆែ វ៉ន់ៈ ក្បាលថ្នល់កំពង់ព្រះឯណោះហ្អែស៎?

ណាប់ៈ ចា៎!

ឆែ វ៉ន់ៈ អីចឹងការងាររគាត់នៅជាប់សហករណ៍រហូតហ្អែស៎?

ណាប់ៈ គេដកហើយបានគេឲ្យទៅ អីចឹងនោះ ។

ឆែ វ៉ន់ៈ ចុះក្រៅពីនាំប្រជាជនធ្វើស្រែណឹងគាត់មាននាំធ្វើអីទៀតក្រៅពីធ្វើស្រែណឹង?

ណាប់ៈ មានធ្វើអី ។

ឆែ វ៉ន់ៈ បា! ចុះអ៊ុំ ម៉ោឃុំតាប៉ុននេះអ៊ុំមានស្គាល់ប្រធានឃុំតាប៉ុនឈ្មោះអីទេ?

ណាប់ៈ អត់ស្គាល់ផង ។

ឆែ វ៉ន់ៈ ចុះទៅដល់អូរម្ទីមានស្គាល់ទេ?

ណាប់ៈ មិនចាំទេខ្ញុំ ។

ឆែ វ៉ន់ៈ ចុះម៉ោដល់សហករណ៍ស្វាយនេះប្រធានសហករណ៍គេឈ្មោះអី?

ណាប់ៈ ខ្ញុំគ្រាន់តែទៅ នៅបណ្តោះអាសន្ន
ពេលបាត់ប្តីទៅខ្ញុំកើតកូនកើតចៅ ទៅក៏ខ្ញុំរត់ម៉ោបងខ្ញុំ ឯ ណោះវិញ ។

ឆែ វ៉ន់ៈ ចុះពេលអ៊ំ ទៅ នៅសហករណ៍ស្វាយណឹងបាននៅជុំគ្នាជាមួយគាត់ដែរអត់?

ណាប់ៈ នៅ បានតែមួយយប់នាំកម្លាំងទៅ ច្រូតបាត់ទៅ ។

ឆែ វ៉ន់ៈ ពេលដូរទៅភ្លាមនៅជាមួយគ្នាបានតែមួយយប់ទេ?

ណាប់ៈ ចា៎!

ឆែ ភ័ន់: ហើយគាត់នាំកម្លាំងទៅ ច្រូតនៅឯណាទៅ ?

ណាប់: នៅក្បាលថ្នល់កាច់រទេះអ៊ីណោះ ។

ឆែ ភ័ន់: អូរ..ក្បាលថ្នល់កាច់រទេះកំពង់ព្រះណឹងហ្អែស៎ ?

ណាប់: មិនដឹងកំពង់ព្រះមិនដឹងអីទេ... ។

ឆែ ភ័ន់: បាទ!

ណាប់: ដល់ពេលក្រោយមៅអត់បានជួបគ្នារហូត?

ឆែ ភ័ន់: ឮដំណឹងថាម៉េចបាន...?

ណាប់: ឮដំណឹងថាគេចាប់យកទៅ ហើយ ។

ឆែ ភ័ន់: ពីណាមៅប្រាប់អ៊ុំថាគេចាប់យកទៅ ហើយ?

ណាប់: កូនចៅ ដែលគេនៅជាមួយ ។

ឆែ ភ័ន់: ឈ្មោះអីទៅ ?

ណាប់: ឈ្មោះហាន ។

ឆែ ភ័ន់: ហានណឹងសព្វថ្ងៃនៅរស់ទេ?

ណាប់: បាត់យូរហើយ ។

ឆែ ភ័ន់: គាត់នាំប្រជាជនទៅ ធ្វើស្រែនៅអីណា?

ណាប់: ទៅ ច្រូតនៅក្បាលថ្នល់ ។

ឆែ ភ័ន់: ក្បាលថ្នល់... អាណឹងគេហៅកំពង់ព្រះឬក៏ព្រះកំពង់?

ណាប់: កំពង់ព្រះ ។

ឆែ ភ័ន់: ហានណឹងត្រូវជាកូនចៅរបស់ជីងគ្រួសាររបស់លោកយាយណឹងហ្អែស៎?

ណាប់: អត់មានបងប្អូនអីទេអ្នកឯទៀតទេតែគ្រាន់តែនៅជាមួយ ។

ឆែ ភ័ន់: ចុះតាំងពីអ៊ុំឮដំណឹងថាគេចាប់គាត់មៅ ហើយក្រោយមៅដែលឮដំណឹងដែរទេ?

ណាប់: អត់ ។

ឆែ ភ័ន់: បាត់ឈឹងហ្នឹង?

ណាប់: បាត់ឈឹង ។

ឆែ ភ័ន់: ចុះរាល់ថ្ងៃនេះអ៊ុំមានដែលស៊ើបសួរដំណឹងពីគាត់ដែរអត់?

ណាប់: មិនដឹងទៅសួរពីណា ។

នែ រ៉ាន់: ចុះមានដែលរកគ្រូទាយអីដែរទេ?

ណាប់: អូ...រឿងគ្រូទាយហ្អែស៎..គេថាឆាប់ ។

នែ រ៉ាន់: ចុះអ៊ុំ ពេលគេចាប់គ្រួសារអ៊ុំណឹង អ៊ំមិញនិយាយថាបន្ទាប់ពីគេចាប់គ្រួសារអ៊ុំ ហើយអ៊ំត្រឡប់ម៉ៅភូមិឃុំនេះវិញ?

ណាប់: ចា៎!

នែ រ៉ាន់: ដូចថាគេចាប់បានរយៈពេលប៉ុន្មានបានអ៊ុំម៉ៅនៅភូមិឃុំនេះវិញ?

ណាប់: បានប្រហែលកន្លះខែ ។

នែ រ៉ាន់: ហឺបានអ៊ុំម៉ៅនៅភូមិឃុំនេះវិញ?

ណាប់: ខ្ញុំនៅតែឯងខ្ញុំមិនហ៊ាននៅ ។

នែ រ៉ាន់: អូអ៊ំត្រូវឆ្លងទន្លេឆ្លងអ្វីដែរហ្អែស៎?

ណាប់: ចា៎!ឆ្លងទន្លេរួចហើយបានកន្លះខែ ។

នែ រ៉ាន់: ឆ្លងទន្លេហើយកន្លះខែ០វានម៉ៅ?

ណាប់: ចា៎!

នែ រ៉ាន់: អីចឹងពេលគេចាប់ដីមណឹងគាត់អត់ទាន់បានឃើញមុខកូនក្រោយទេ?

ណាប់: នៅ..កូននៅនឹងពោះនៅឡើយ ចាប់បានពីរយប់បានកើត ។

នែ រ៉ាន់: ចាប់បានពីរយប់កើត..ដល់ខែត្រូវកើតហើយ...កូនក្រោយនេះកូនប្រុសឬស្រី?

ណាប់: ប្រុស ។

នែ រ៉ាន់: សព្វថ្ងៃនៅដែរហ្អែស៎?

ណាប់: នៅ ។

នែ រ៉ាន់: ចុះអ៊ុំកាលជំនាន់ខ្មែរក្រហមគេឲ្យអ៊ុំធ្វើអីដែរ?

ណាប់: ខ្ញុំមើលកូន ។

នែ រ៉ាន់: អត់មានធ្វើស្រែធ្វើអីទេ?

ណាប់: អត់ ។

នែ រ៉ាន់: ចុះនៅមើលកូនអ៊ីចឹងរបបហូបចុកអីគេឲ្យយើងយ៉ាងម៉េចដែរ?

ណាប់: គេឲ្យយើងដូចតែគ្នាអីចឹង បើថាបាយដូចគ្នាអីចឹងទៅ បើថាបបរដូចគ្នាទៅ ។

នែ រ៉ាន់: ចុះដូចថាមានគ្រួសារធ្វើសហករណ៍អីចឹងយើងអត់បានរបបលើសគេទេហ្អែស៎?

ណាប់ៈ អត់ទេ ។

ឆៃ រ៉ាន់ៈ របបស្មើគ្នា...?

ណាប់ៈ ស្មើគ្នា ។

ឆៃ រ៉ាន់ៈ គេឲ្យហូបម៉េចទៅរបបណឹង?

ណាប់ៈ គេបើកឲ្យយើងទៅ ។

ឆៃ រ៉ាន់ៈ មិនមែនឲ្យហូបនៅសហករណ៍ទេអីចឹង?

ណាប់ៈ គេមានកាស៊ីនគេ គេទៅដាំទៅស្ទួមទៅ គេបើកឲ្យបែកគ្នាទៅ ។

ឆៃ រ៉ាន់ៈ កាលណឹងគេឲ្យបាយប៉ុន្មានពេលដែរ?

ណាប់ៈ ពីរពេល ។

ឆៃ រ៉ាន់ៈ ព្រឹកមួយពេលល្ងាចមួយពេល?

ណាប់ៈ ល្ងាចហើយនឹងព្រឹក ។

ឆៃ រ៉ាន់ៈ ព្រឹកម៉ោ១១ណឹងហ្អែស៎?

ណាប់ៈ ចា៎!

ឆៃ រ៉ាន់ៈ កាលណឹងបានបាយឬក៏បបរខ្លះដែរ?

ណាប់ៈ បាយខ្លះបបរខ្លះ ។

ឆៃ រ៉ាន់ៈ បបរខាប់ឬរាវ?

ណាប់ៈ បបររាវ ។

ឆៃ រ៉ាន់ៈ ចុះមានម្ហូបដែរ?

ណាប់ៈ គ្មានម្ហូបទេ...សម្លរត្រកួន ។

ឆៃ រ៉ាន់ៈ ចុះដូចគ្រួសារនៅខាងសហករណ៍អីចឹងអត់សុំបាយគេហូបឲ្យបានច្រើនទេ?

ណាប់ៈ អត់ទេអត់បានទេ ។

ឆៃ រ៉ាន់ៈ ចុះដឹមណឹងហូបអីចឹងដែរ?

ណាប់ៈ ចា៎! ហូបដូចតែគ្នាណឹង ចូលទៅកាស៊ីនដូចតែគ្នាណឹង ។

ឆៃ រ៉ាន់ៈ ចុះអ៊ុំ ធ្លាប់ឆ្លងទន្លេសម័យខ្មែរក្រហមប៉ុន្មានដង ១ ដងឬក៏ ២ដង?

ណាប់ៈ ម្តង...នៅក្នុងព្រៃម្តង ។

ឆៃ រ៉ាន់ៈ នៅក្នុងព្រៃម្តង ពេលគៀទៅព្រៃភានាមណឹងហ្អែស៎?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ត្រឡប់មោ៉ ៧៥ ណឹងឆ្លងទន្លេម្ដងទៀត ។

ណាប់៖ មួយទៀត ។

នៃ វ៉ាន់៖ អាណឹងពេលគេចាប់ប្ដីហើយហ្អែស៎?

ណាប់៖ នៅ ។

នៃ វ៉ាន់៖ អីចឹងកូនអ៊ុំទាំងអស់ប៉ុន្មាន?

ណាប់៖ ម៉ាគំបរ ។

នៃ វ៉ាន់៖ ៤ ហ្អែស៎?

ណាប់៖ ចា៎!

នៃ វ៉ាន់៖ ឆ្លងជិតខ្មែរក្រហមពីរ?

ណាប់៖ តែមួយទេ.. អើវាពីរហើយឆ្លងមោ៉ដាប់ ៧៥ ណឹងមួយទៀត ២ ។

នៃ វ៉ាន់៖ មោ៉ទល់ ៧៥ មួយទៀត ២... ។

ណាប់៖ មីបងមុននោះកើតមុនខ្មែរក្រហម ។

នៃ វ៉ាន់៖ អីចឹងម៉ាឆ្នាំ ១?

ណាប់៖ ទេម៉ាឆ្នាំមួយម៉េច...

នៃ វ៉ាន់៖ កាលឆ្នាំ ៧២ បានកូន ១ទៀត ។

ណាប់៖ កាលទៅព្រៃដើម នឹងពោះ ទៅដល់ព្រៃកើត ។

នៃ វ៉ាន់៖ កើតពេលនៅព្រៃនាមណឹង?

ណាប់៖ ចា៎! ៧៥ មោ៉វិញដើមមួយទៀត ។

នៃ វ៉ាន់៖ ណឹងកើតមួយទៀតណឹងគេចាប់គ្រួសារយកទៅ?

ណាប់៖ នៅទេ ។

នៃ វ៉ាន់៖ កើតមួយទៀតកើឆ្នាំណា?

ណាប់៖ ឆ្នាំម្សាញ់ចុងបង្ហើយ ។

នៃ វ៉ាន់៖ ក្រោយមោ៉បានកើតមួយទៀត?

ណាប់៖ អាកើតមួយទៀតចុងបង្ហើយណឹង... ។

ផៃ ភ៊ន់៖ អ៊ីចឹងទើបតែកើតកូនបានតែ ២

ថ្ងៃទេ...ពេលកើតកូនណឹងគាត់អត់បានជួបមុខទេហ្អែស៎?

ណាប់៖ អត់ទេពេលចាប់គាត់ពីរថ្ងៃហើយបានកូនណឹងវាកើត ។

ផៃ ភ៊ន់៖ ប្អា! គាត់អត់បានជួបមុខកូនអត់បានស្គាល់មុខកូនទេអ៊ីចឹង...

ណាប់៖ ចុះបានស្គាល់ម៉េចបើនៅក្នុងពោះនៅឡើយ ។

ផៃ ភ៊ន់៖ អ៊ីចឹងកូនទាំងអស់ ៣ ឬក៏ ៤ ?

ណាប់៖ ៤ ។

ផៃ ភ៊ន់៖ អ៊ីចឹងមុនណឹងកើតបាន ២ ហើយពេលជម្លៀសទៅព្រៃណឹងកើតបាន ២ ហើយ ។

ណាប់៖ កើតបាន ១ ហើយដើមនៅក្នុងពោះ ១ទៀត ។

ផៃ ភ៊ន់៖ ទៅកើតនៅព្រៃបាន ១ អ៊ីចឹងឡើង ២ ដល់បានដល់ជំនាន់ខ្មែរក្រហមអ៊ុំថា ១ ទៀត..?

ណាប់៖ ដល់ឆ្នាំ ៧៥ ណឹងកើត ១ ទៀត ។

ផៃ ភ៊ន់៖ កើនៅអីណាអាណឹង?

ណាប់៖ កើតនៅតាប៉ុនអីណោះ ។

ផៃ ភ៊ន់៖ ពេទ្យគេស្រួលដែរហ្អែស៎?

ណាប់៖ ...?

ផៃ ភ៊ន់៖ ពេលអ៊ុំមៅដល់តាប៉ុមណឹងកើត ១ ទៀត?

ណាប់៖ ចា៎!

ផៃ ភ៊ន់៖ ពេទ្យគេល្អដែរហ្អែស៎?

ណាប់៖ អត់មានពេទ្យទេ កើតឆ្មបខ្មែរយើងណឹង ។

ផៃ ភ៊ន់៖ បាទ! ដល់ពេលគេចាប់គ្រួសារណឹងកើត ១ ទៀត?

ណាប់៖ ចា៎!

ផៃ ភ៊ន់៖ អ៊ីចឹងទាំងអស់ ៤ ស្រីប៉ុន្មាន? ប្រុសប៉ុន្មាន?

ណាប់៖ ស្រី ១ ប្រុស ៣ ។

ផៃ ភ៊ន់៖ សព្វថ្ងៃនៅទាំងអស់គ្នាហ្អែស៎?

ណាប់៖ អត់ទេនៅតែ ៣ ស្លាប់ ១ បាត់ហើយ ។

ផៃ ភ៊ន់៖ ស្លាប់មួយណា?

ណាប់ៈ ស្លាប់អាកើតនៅព្រៃ ។

ឆៃ វ៉ាន់ៈ ស្លាប់ពេល ៧៩ ហើយហ្អែ៎?

ណាប់ៈ អត់ទេ..ស្លាប់ពេលម៉ៅនៅតាប៉ុន ។

ឆៃ វ៉ាន់ៈ ចឹបានស្លាប់អ៊ុំ ?

ណាប់ៈ ឈឺមើលអត់ជា ។

ឆៃ វ៉ាន់ៈ ឈឺអីគេអាណឹង?

ណាប់ៈ មិនដឹងស្រាប់តែស្វិតទៅៗងាប់ទៅ ។

ឆៃ វ៉ាន់ៈ អីចឹងអ៊ុំជាប់មើលកូនរហូតអត់បានធ្វើការ ។

ណាប់ៈ អត់មានធ្វើការងារអីកើត ។

ឆៃ វ៉ាន់ៈ ហើយរបបបានស្មើគេដែរ?

ណាប់ៈ ចា៎! មើលកូនខ្លួនឯងផងមើលកូនគេផង ។

ឆៃ វ៉ាន់ៈ ចុះដូចថាមានពួក ១៧ គេជម្លៀសចូលម៉ៅច្រើនទេ?

ណាប់ៈ ១៧ ម៉េចទៅ..?

ឆៃ វ៉ាន់ៈ ពួកប្រជាជនថ្មីហ្អាស៎ពួកពីភ្នំពេញអីមានឃើញម៉ៅទេ?

ណាប់ៈ អត់...អត់ស្គាល់ ។

ឆៃ វ៉ាន់ៈ អត់ស្គាល់ទេ...

ណាប់ៈ ចា៎!

ឆៃ វ៉ាន់ៈ អ៊ុំនៅតែផ្ទះរហូតអត់ដឹងទេហ្អែស៎?

ណាប់ៈ អត់ដឹងទេ ។

ឆៃ វ៉ាន់ៈ ចុះដូចថាគ្រួសារធ្វើការខាងសហករណ៍អីចឹងយើងទ្រង់មានសិទ្ធជាងប្រជាជនផ្សេងដែរឬក៏ម៉េច? ដូចថាយើងទ្រង់មានសិទ្ធបានម្ហូបបានអីច្រើនជាងប្រជាជនផ្សេងដែរហ្អែស៎?

ណាប់ៈ អត់ទេ...ក្រែងគេផ្សេង បើខ្ញុំអត់ទេ ។

ឆៃ វ៉ាន់ៈ ស្មើគ្នា ។

ណាប់ៈ ចា៎! ដូចតែគេអីចឹង ។

ឆៃ វ៉ាន់ៈ បា! អីចឹងអ៊ុំនៅមើលរហូតពេលគេចាប់គ្រួសារទៅ គេមានឲ្យទៅធ្វើការអីដែរអត់?

ណាប់៖ អត់ទេ ។

នៃ រ៉ាន់៖ អត់ដដែល មៅស្រុកភូមិនេះវិញឬក៏នៅ មើលកូនដដែល?

ណាប់៖ ...?

នៃ រ៉ាន់៖ ចុះពួនារតីមៅអីចឹងវាអត់មានបន្ទុឲ្យអុំ ធ្វើការអីទេហ៎?

ណាប់៖ ធ្វើដែរគេឲ្យទៅស្ទូងទៅ អីដែរណឹង ។

នៃ រ៉ាន់៖ កូនចុងក្រោយណឹងហ្អែស?

ណាប់៖ ចា៎!កូនចុងក្រោយណឹង ។

នៃ រ៉ាន់៖ កើតហើយបានប៉ុន្មានខែបានគេឲ្យទៅ ធ្វើការ?

ណាប់៖ គេចេះតែប្រើយើងទៅ រកពប់ខែឯណាបាន ។

នៃ រ៉ាន់៖ ដូចថាយើងកើតកូនបាន ១ ខែគេឲ្យយើងធ្វើការទៅ?

ណាប់៖ ចា៎!

នៃ រ៉ាន់៖ ធ្វើការខាងអីទៅ?

ណាប់៖ ធ្វើការកាប់ព្រៃអីទៅ ។

នៃ រ៉ាន់៖ យើងសុំគេសំរាកអត់បានទេ?

ណាប់៖ អត់ទេ តែហ៊ានសំរាក...

នៃ រ៉ាន់៖ អាណឹងពេលពួកនារតីចូលមៅ?

ណាប់៖ ចា៎!

នៃ រ៉ាន់៖ អុំមានឃើញអីប្លែកទេ ពេលពួកនារតីកាន់ ហើយពួកពាយ័ព្យកាន់អុំ ឃើញមានអ្វីប្លែកគ្នាទេ?

ណាប់៖ មិនដឹងដែរខ្ញុំដូចមិនសូវយល់ទេ ។

នៃ រ៉ាន់៖ មិនសូវយល់ទេ?

ណាប់៖ ចា៎! គ្រាន់តែឃើញតែបបរអីចឹង ។

នៃ រ៉ាន់៖ ចុះកាលពួកនារតីមៅគេបើកបបរដែរឬក៏បើកបាយ?

ណាប់៖ បបរ ។

នៃ រ៉ាន់៖ បបរទាំងពីរពេល?

ណាប់៖ ចា៎!

ផៃ រ៉ាន់ៈ អត់ដែលបានបាយទេ?

ណាប់ៈ បានបាយតែកាលឆ្នាំ ៧៩ ទេ ជិតពីណឹងទៅឈប់បានបាយហើយ ។

ផៃ រ៉ាន់ៈ បបររហូត?

ណាប់ៈ ចាំ!

ផៃ រ៉ាន់ៈ ចុះអ៊ុំដូចថាពួកពាយ័ព្យកាន់ហើយ និងពួកនារតីកាន់ពីណាធូជាងពីណាតឹងជាងទៅ?

ណាប់ៈ មិនដឹង ។

ផៃ រ៉ាន់ៈ ពេលពួកនារតីមោកាន់ធូជាងឬក៏តឹងជាង?

ណាប់ៈ បែបដូចតែគ្នាទេឬក៏តឹងជាងផងក៏មិនដឹង ព្រោះបបររាវទៅ ៗ នៅតែទឹកទទេហើយគេ
ជម្លៀសទៅទៀត ។

ផៃ រ៉ាន់ៈ បាទ! កាលណឹងគេជម្លៀសចេញពីយួនគេចចេញមុនណឹងណា៎...

ណាប់ៈ ទេមិនជម្លៀសគេចពីយួនទេ ជម្លៀសយើងឲ្យផុតទៅ ។

ផៃ រ៉ាន់ៈ បាទ! ចុះពេលអ៊ុំកើតកូនក្រោយបាន ១ ខែអ៊ុំសុំគេមោនៅស្រុកភូមិវិញ ។

ណាប់ៈ បានកន្លះខែ...

ផៃ រ៉ាន់ៈ បានកន្លះខែ...

ណាប់ៈ ចាំ!

ផៃ រ៉ាន់ៈ សុំគេៗឲ្យមោដែរ?

ណាប់ៈ គេអត់ឲ្យមោទេ តែខ្ញុំរត់មោ ។

ផៃ រ៉ាន់ៈ គេអត់ចាប់ទេអីចឹង?

ណាប់ៈ ពេលស្វាត់គេចខុសពីកន្លែងគេយាម ។

ផៃ រ៉ាន់ៈ កាលណឹងអ៊ុំទៅសុំពីណាគេ?

ណាប់ៈ នៅនឹងស្វាយណឹងឈ្មោះតាគាត់ តាខេន មិនដឹងទេ គាត់ណឹងប្រធានសហករណ៍កាន់ក្តាប់ខាង
ឃ្មាំងស្រូវ ។ សុំគាត់មោគាត់ថាអត់ឲ្យមោទេ
ហើយខ្ញុំទៅសុំម្តងទៀតតាឯងឲ្យខ្ញុំទៅក៏ខ្ញុំទៅ មិនឲ្យខ្ញុំទៅក៏ខ្ញុំទៅ ខ្ញុំតាំងចិត្តអីចឹង ។

ផៃ រ៉ាន់ៈ អ៊ុំរត់មោ?

ណាប់ៈ ចាំ!

ផៃ រ៉ាន់ៈ ហីគេអត់មោតាមរកអីទេអីចឹង?

ណាប់៖ អត់

នៃ ភ៉ន់៖ តាខេន ណឹងគាត់ខាងនារតីឬក៏ខាងពាយ័ព្យ?

ណាប់៖ ខាងពួកខ្មែរយើងណឹងមិនមែននារតីទេ ។

នៃ ភ៉ន់៖ ខាងពួកតាកែវអីណឹង...ខាងពួកទើបចូលមោ៉ថ្មីឬក៏ពួកនៅចាស់?

ណាប់៖ មិនដែលស្គាល់ផង ទើបតែឮសូកាលខ្ញុំទៅ នៅមិនដែលស្គាល់ទេ...

នៃ ភ៉ន់៖ ដល់អ៊ុំសុំមោ៉នៅអីណោះគេឲ្យធ្វើស្រែធ្វើចំការអីដែរ?

ណាប់៖ អត់...គេឲ្យទៅកាប់ព្រៃ ។

នៃ ភ៉ន់៖ កាប់ព្រៃនៅឯណា?

ណាប់៖ នៅរហាចក ។

នៃ ភ៉ន់៖ កាប់ព្រៃបានរយៈពេលប៉ុន្មានទៅអ៊ុំ?

ណាប់៖ កាប់បានពីរបីថ្ងៃគេហៅខ្ញុំឡើងមោ៉វិញមោ៉ គេចាប់ខ្ញុំទៀត ។

នៃ ភ៉ន់៖ អូ...ម៉េចគេចាប់អ៊ុំ?

ណាប់៖ គេថាពាក់ព័ន្ធ ។

នៃ ភ៉ន់៖ កម្មាភិបាល?

ណាប់៖ ចា៎!

នៃ ភ៉ន់៖ អូ...គេចោទថាអីចឹង ។

ណាប់៖ ចា៎!

នៃ ភ៉ន់៖ អ្នកដែលចាប់ពីណាគេអ៊ុំស្គាល់ទេ?

ណាប់៖ អ្នកណាស្គាល់គេបរទេះមោ៉យប់មោ៉ដឹកទៅ ។

នៃ ភ៉ន់៖ ចុះកូនចៅអ៊ុំអីពេលណឹងនៅជុំគ្នាដែរ?

ណាប់៖ ចា៎!

នៃ ភ៉ន់៖ ពេលគេចាប់ទៅ គេយកទាំងកូនទៅដែរ?

ណាប់៖ ចា៎! យកទៅប៉ុន្តែគ្រាន់តែទៅដល់កន្លែងសូណាបា៉ គេទម្លាក់ចោលត្រង់ណឹង គេថាឲ្យមោ៉វិញ ។

នៃ ភ៉ន់៖ កន្លែងអីគេកន្លែងណឹង សូណាបា៉?

ណាប់៖ ចា៎!

ឆែ ភ៉ន់៖ សូណាបុាំណឹងនៅក្នុងភូមិឃុំអីដែរ?

ណាប់៖ នៅអន្ទង់វិលណឹង ។

ឆែ ភ៉ន់៖ អូ..នៅជិតអន្ទង់វិលណឹងដែរ...សូណាបុាំ...

ណាប់៖ ចាំ!

ឆែ ភ៉ន់៖ អ្នកដែលមោយកអ៊ុំទៅណឹងស្គាល់ទេ?

ណាប់៖ អត់ស្គាល់គេផង ។

ឆែ ភ៉ន់៖ ហឺពេលទៅដល់សូណាបុាំណឹងអ្នកកាន់កាប់នៅហ្នឹងគេឲ្យយកមោវិញ?

ណាប់៖ ចាំ!

ឆែ ភ៉ន់៖ ឈ្មោះអីអ្នកដែលឲ្យយកអ៊ុំមោវិញណឹង?

ណាប់៖ អត់ស្គាល់ទេ គ្រាន់តែអាអ្នកដឹងមោណឹងថាមេចឲ្យដឹងគាត់មោ ហើយគេថាទេដឹកគាត់ទៅ
វិញទៅ នៅសហករណ៍ណាដឹកគាត់ទៅសហករណ៍ណឹងវិញទៅ
ហើយក៏គេដឹកមោវិញមោ ។

ឆែ ភ៉ន់៖ ដឹកមោវិញអ៊ុំដល់ពេលការងារធម្មតា?

ណាប់៖ ចាំ!កាប់គាស់ដីដាំដំឡូងដាំអីនឹងគេទៅណា ។

ឆែ ភ៉ន់៖ អ៊ុំនៅធ្វើអីចឹងរហូតដល់វៀតណាមចូលហ្អែស?

ណាប់៖ នៅធ្វើអីចឹងអីគេជម្លៀសទៅទៀត គេជម្លៀសទៅនៅសង្កែដុសទៅនៅឯណា
ទៅភ្នំធិបតី អីណា ។ ជម្លៀសទៅអីណឹងបានទៅប្រូតនិងគេ
ពេលកំពុងប្រូតៗ វៀតណាមចូលមោដល់ រត់កាត់គ្រាប់មោឡើងនៅក្បាលខ្មោចនេះ ។

ឆែ ភ៉ន់៖ អូ..ភូមិប្រឡាយខ្មោចនេះ...

ណាប់៖ មិនមែនទេ ក្បាលខ្មោច ។

ឆែ ភ៉ន់៖ អូ..នៅស្រុកថ្មគោលណឹងហ្អែស?

ណាប់៖ ខ្ញុំរត់កាត់តាមណឹងឯង ។

ឆែ ភ៉ន់៖ អ៊ុំរត់មោតែម្នាក់ឯងទេ?

ណាប់៖ កូនអីមោប្រសេកប្រសាច ប្រជាជនអីមោព្រោងព្រាតមោណា គ្រាប់បេះតែបាញ់ប្រាវៗ
ទេ?

ឆែ ភ៉ន់៖ ចុះអ៊ុំកាលជំនាន់ខ្មែរក្រហមដែលឃើញគេចាប់ខ្លួនឬក៏ធ្វើទារុណកម្មមនុស្សដែរអត់?

ណាប់៖ អត់ដែលបានឃើញទេ ។

ផៃ រ៉ាន់៖ ចុះមានដែលឃើញអ្នកដែលធ្វើការជាមួយបាត់ខ្លួនទេ?

ណាប់៖ អត់ដែរ ។

ផៃ រ៉ាន់៖ ចុះអ៊ុំរត់ពេលវៀតណាមចូលម៉ោណឹងរត់ទៅដល់ឆ្នាំណាបានត្រឡប់ម៉ោដល់ស្រុកភូមិនេះវិញ?

ណាប់៖ ៧៩ ។

ផៃ រ៉ាន់៖ ៧៩ អ៊ុំ ម៉ោស្រុកភូមិវិញដែរ?

ណាប់៖ ចា៎!

ផៃ រ៉ាន់៖ ពេលម៉ោដល់អ៊ុំ បាត់បង់សាច់ញាតិអស់ប៉ុន្មាននាក់ដែរ?

ណាប់៖ មានបាត់អីម៉ោជុំគ្នាទាំងអស់ ទើបតែមាជំនាន់ទាហានណឹងបានបែកបងប្អូន ។

ផៃ រ៉ាន់៖ ចុះអ៊ុំដូចថាធ្លាប់បានឆ្លងកាត់សម័យខ្មែរក្រហមអីចឹងអ៊ុំគិតថារបបណឹងយ៉ាងម៉េចដែរ?

ណាប់៖ អត់ដឹងទេ គេថាខ្មែរក្រហមប្រហម នឹងគេទៅ ។

ផៃ រ៉ាន់៖ ហើអ៊ុំយល់ថារបបណឹងជារបបយ៉ាងម៉េចដែរ របបខ្មែរក្រហមដែលគេកាន់កាប់ណឹង វាល្អស្រួលត្រង់ណា?

ណាប់៖ វាមិនស្រួលដូចយើងសព្វថ្ងៃអីចេះទេ ។

ផៃ រ៉ាន់៖ បា! ពិបាកដែរអីចឹងហ្អែស៎?

ណាប់៖ ចា៎!

ផៃ រ៉ាន់៖ ពិបាកលើអីខ្លះទៅ?

ណាប់៖ ពិបាកនឹងហូបចុករកអីវាមិនបានកម្មសិទ្ធខ្លួនយើងណឹងណ៎ ។

ផៃ រ៉ាន់៖ បាទ!

ណាប់៖ ធ្វើអីក៏រួម ។

ផៃ រ៉ាន់៖ ចុះដូចថាធ្លាប់ឆ្លងកាត់សម័យណឹង ធ្លាប់និយាយរឿងរ៉ាវអ៊ីដែលអ៊ុំធ្លាប់ឆ្លងកាត់ណឹងឲ្យកូនចៅស្តាប់ដែរអត់?

ណាប់៖ មិនដែលនិយាយទេ ព្រោះនៅតូចៗវាមិនចេះស្តាប់ទេ ។

ផៃ រ៉ាន់៖ អ៊ុំមានដែលនិយាយទេ?

ណាប់៖ ខ្ញុំនិយាយដែរ ប្រាប់វាឲ្យខំរកស៊ីទៅ ព្រោះជំនាន់មុនវាពិបាក ។

ឆៃ វ៉ាន់: ចុះអ៊ុំសព្វថ្ងៃនេះមានដែលឮពត៌មានឬក៏អ្នកស្រុកនិយាយគ្នាពីរឿងការបង្កើតតុលាការ ដើម្បី កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែរអត់?

ណាប់: អត់ដឹង ។

ឆៃ វ៉ាន់: ពីរឿងគេកាត់ទោសខ្មែរក្រហមហ្នឹងដែលឮទេ?

ណាប់: អត់ដែលឮទេ ។

ឆៃ វ៉ាន់: អ៊ុំសព្វថ្ងៃនេះខាងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិគេបានព្រមព្រៀងគ្នា រៀបចំសាលាក្តីដើម្បីកាត់ ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូច នួន ជា,អៀង សារី,ខៀវ សំផន,តាម៉ុក អីណឹងហ្នឹងអ៊ុំ ។ ចុះបើសិនជាអ៊ុំដឹងអ៊ុំមានការគាំទ្រក្នុងការបង្កើតតុលាការ ណឹងដែរឬក៏អត់ចង់ទេ?

ណាប់: អត់ដឹងទេ ។

ឆៃ វ៉ាន់: ដូចថាអ៊ុំចង់ឲ្យគេយកពួកមេខ្មែរក្រហមទាំងអស់ណឹងមៅកាត់ទោសដែរទេ?

ណាប់: ....?

ឆៃ វ៉ាន់: ចុះអ៊ុំយល់យ៉ាងម៉េចដែរចំពោះពាក្យយុត្តិធម៌?

ណាប់: មិនដែលបានរៀន នឹងគេផងអត់យល់ទេ ។

ឆៃ វ៉ាន់: បាទខ្ញុំដូចអត់មានអីសួរអ៊ុំទៀតទេ អ៊ុំមានអ្វីដែលអ៊ុំគិតថាសំខាន់ហើយខ្ញុំអត់បានសួរនាំ ដែលទាក់ទង និងរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហម ទាក់ទង និងជីវិតអ៊ុំដែរអត់?

ណាប់: គ្មានមានអីទេ ។

ឆៃ វ៉ាន់: បាទ! បើអីចឹងខ្ញុំអរគុណអ៊ុំច្រើនដែលចំណាយពេលនិយាយរឿងរ៉ាវគ្រួសាររបស់លោកអ៊ុំ ឈ្មោះ ប៉ុក ជឹមណឹង ហើយនិងរឿងរបស់លោកអ៊ុំផ្ទាល់..អីចឹងអរគុណលោកអ៊ុំ ច្រើន ។

-ចប់-